# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រុមហ៊ុន ផាក ហេនប៊ែក (ខេមបូឌា) ឯ.ក

### កិច្ចព្រមព្រៀង
### រវាង

ក្រុមហ៊ុន ផាក ហេនប៊ែក (ខេមបូឌា) ឯ.ក ជាមួយតំណាងកម្មករ និង សហជីព ប្រចាំក្រុមហ៊ុន ឆ្នាំពីរពាន់ម្ភៃពីរ ខែ សីហា ថ្ងៃទី ០៦ វេលាម៉ោង ១ និង ០០នាទី ថ្ងៃត្រង់នៅការិយាល័យក្រុមហ៊ុន ផាក ហេនប៊ែក (ខេមបូឌា) ឯ.ក មានកិច្ចប្រជុំពិភាក្សា រវាងតំណាងក្រុមហ៊ុន ប្រតិភូបុគ្គលិក និង ថ្នាក់ដឹកនាំសហជីព អភិវឌ្ឍន៍ចលនាការងារកម្ពុជាប្រចាំរោងចក្រ។ ក្រោយបានប្រជុំពិភាក្សាភាគីទាំងពីរបានយល់ព្រមព្រៀងគ្នាដូចខាងក្រោម៖

១-ភាគីទាំងពីរយល់ព្រមព្យួរការងាររយៈពេលពីរខែចាប់ពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី១៥ ខែ តុលា ឆ្នាំ ២០២២ ចំពោះកម្មករ និយោជិត១៤២០នាក់ មានផ្នែកដេរ ផ្នែកបិទការ ផ្នែកពិនិត្យគុណភាព ផ្នែកវេចខ្ចប់ ផ្នែកតុកាត់ ផ្នែកការិយាល័យ ផ្នែកឃ្លាំង ផ្នែកជាងភ្លើង ផ្នែកជាងម៉ាស៊ីន ផ្នែកសន្តិសុខ និង ផ្នែកអនាម័យ។

មូលហេតុដោយសារអ្នកបញ្ជាទិញផ្អាកការបញ្ជាទិញ ព្រោះប្រទេសទាំងនោះរងផលប៉ះពាល់ពីផ្នែកសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ។

២-ភាគីកម្មករនិយោកជិតយល់ព្រមទទួលប្រាក់ឧបត្ថម្ភ៥០ដុល្លារអាមេរិក ពីភាគីនិយោជកក្នុង១ខែ (មួយខែ២៦ថ្ងៃ) សំរាប់រយៈពេលព្យួរការងារនេះ។

៣-ក្រុមហ៊ុននិងបើកជូនប្រាក់ឧបត្ថម្ភ៥០ដុល្លាអាមេរិកនេះជូនកម្មករនិយោជិត១ខែម្តង។

៤-បងប្អូនត្រូវត្រលប់ចូលមកធ្វើការវិញនាថ្ងៃទី១៧ ខែ តុលា ឆ្នាំ ២០២២ ក្នុងករណីបងប្អូន កម្មករមិនបានចូលធ្វើការតាមការកំណត់នេះទេ ក្រុមហ៊ុននឹងអនុវត្តន៍តាមច្បាប់ស្តីពីការងារ និងបទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន។

កិច្ចព្រមព្រៀងនេះ ចាប់អនុវត្តន៏និងមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

កំពង់ស្ពឺ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០២២

**តំណាងក្រុមហ៊ុន**

ក្រុមហ៊ុន ផាក ហេនប៊ែក (ខេមបូឌា) ឯ.ក
PARK HANDBAG (CAMBODIA) CO., LTD.
KINGDOM OF CAMBODIA

**ស្នាមមេដៃតំណាងកម្មករនិយោជិត**

១ ........ ២ ........

៣ ........ ៤ ........

៥ ........ ៦ ........

៧ ........ ៨ ........